នៃបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តបាត់ដំបង និងគណៈអាណាភាព ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ តាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.នាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ស ខេង

★★★

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០០

## សេចក្តីសំរេចលេខ ០៧ សសរ

### ស្តីពី ការបង្កើតគណៈកម្មការ វិទ្យាសាស្ត្រ និង បច្ចេកទេសរបស់ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការកែសំរួល ការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

-យោងតាមសំណូមពរការងារចាំបាច់

### សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការវិទ្យាសាស្ត្រ និងបច្ចេកទេស ហៅកាត់ “ គ.វ.ប ឬ S.T.C“ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម ពៅ សាមី | អគ្គលេខាធិការ គ.ជ.គ.ម | ប្រធាន |
| ២-ឯកឧត្តម ផាន់ ខុន | អគ្គលេខាធិការ គ.ជ.គ.អ | អនុប្រធាន |
| ៣-ឯកឧត្តម អ៊ុក ដាមរី | អនុប្រធានទី១ កាកបាទក្រហមកម្ពុជា | អនុប្រធាន |
| ៤-លោក ហង្ស ម៉ុណ្ណាត់ | អគ្គនាយករងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | សមាជិក |

| | | |
|---|---|---|
| ៥-លោក តឹង តារ៉ាទ្រី | នាយក នាយកដ្ឋានផ្លូវទឹក ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៦-លោក ស៊ុ សុទុធ | ប្រធាននាយកដ្ឋាន វាយតំលៃធនធានធម្មជាតិ និងទិន្នន័យបរិស្ថាន នៃក្រសួងបរិស្ថាន | សមាជិក |
| ៧-លោក ឡេង នី | ប្រធាននាយកដ្ឋានផែនការស្ថិតិ និងសហប្រតិបត្តិការ អន្តរជាតិ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨-លោកគ្រូពេទ្យបណ្ឌិត ឃួន អេងមុនី | អនុប្រធាននាយកដ្ឋានការពារសុខភាពក្រសួងសុខាភិបាល | សមាជិក |
| ៩-លោកឧត្តមសេនីយ៍ត្រី គង់ មុនី | មេបញ្ជាការរងកងទ័ពជើងអាកាស នៃក្រសួងការពារជាតិ | សមាជិក |
| ១០-លោក និត្យ ទន្លា | អនុប្រធាននាយកដ្ឋាន ទទួលបន្ទុកការិយាល័យបញ្ជាការហោះហើរ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល កម្ពុជា | សមាជិក |
| ១១-ប្រធាននាយកដ្ឋាន | រដ្ឋបាលនិងហិរញ្ញកិច្ច នៃអគ្គលេខាធិការដ្ឋាន "គ.ជ.គ.ម" | សមាជិក |
| ១២-ប្រធាននាយកដ្ឋាន | មជ្ឈមណ្ឌលប្រចាំសង្គ្រោះបន្ទាន់ និងបណ្តុះបណ្តាល នៃអគ្គលេខាធិការដ្ឋាន "គ.ជ.គ.ម" | សមាជិក |
| ១៣-ប្រធាននាយកដ្ឋាន | សំរាកសំរួលសង្គ្រោះបន្ទាន់ និងស្តារឡើងវិញ នៃអគ្គលេខាធិការដ្ឋាន "គ.ជ.គ.ម" | សមាជិក |
| ១៤-ប្រធាននាយកដ្ឋាន | ស្វែងរកនិងសង្គ្រោះនៃអគ្គលេខាធិការដ្ឋាន "គ.ជ.គ.ម" | សមាជិក |
| ១៥-លោក ហម សុធីរ | ប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាលទូទៅក្រសួងមហាផ្ទៃ | សមាជិក |
| ១៦-លោក សោ បានហ៊ាន | មន្ត្រីអគ្គលេខាធិការដ្ឋាន "គ.ជ.គ.ម" | លេខាធិការ |

ប្រការ ២ : គណៈកម្មការវិទ្យាសាស្ត្រនិងបច្ចេកទេសមានតួនាទីនិងភារកិច្ចដូចតទៅ :

-កំណត់ការងារនិងធ្វើសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ លើកផែនការ និងទំរង់បែបបទការងារគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា ។

-វិភាគវាយតំលៃផ្តល់យោបល់នូវរាល់បាតុភូតជាគ្រោះមហន្តរាយដែលកើតមានឡើង ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

-ពិគ្រោះយោបល់ ដើម្បីជួយគាំទ្រដល់មុខងាររបស់អគ្គលេខាធិការដ្ឋាន "គ.ជ.គ.ម" ។

-លើកកំរោងសកម្មភាព កម្មវិធី អន្តរក្រសួង ដើម្បីអនុវត្តការងារគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា ។

-ពិនិត្យផ្តល់យោបល់ការងារបច្ចេកទេសគ្រប់គ្រងគ្រោះមហន្តរាយរបស់ក្រសួងពាក់ព័ន្ធ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ខេត្ត-ក្រុង និងក្រុមសាជីវកម្ម ។

-ឧបត្ថម្ភផ្នែកបច្ចេកទេស និងជូនយោបល់លើសំណើកំណត់ការប្រកាសអាសន្នថ្នាក់ជាតិរបស់អគ្គលេខាធិការដ្ឋាន "គ.ជ.គ.ម" ។

ប្រការ ៣ : សមាជិកតំណាងអោយក្រសួងពាក់ព័ន្ធនីមួយៗ ត្រូវទទួលខុសត្រូវក្នុងក្របខ័ណ្ឌសមត្ថកិច្ច ភារកិច្ចដែលបានកំណត់ក្នុងមាត្រា២ និងត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន "គ.វ.ក." ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ស ខេង

***

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០០

**សេចក្តីសំរេច លេខ ០៨ សសរ**

**ស្តីពី ការបង្កើត**

**គណៈកម្មការអន្តរក្រសួង ចុះពិនិត្យទីតាំងសំណង់អនាធិបតេយ្យ**

**នៅភ្នំព្រះរាជទ្រព្យ (ភ្នំខ្នុក្ក)**

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់